**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ១៨៦
ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០២
**សាលដីកា**
លេខៈ២៩៣
ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០២

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០២ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ............ ជាប្រធាន
២-លោក ........... ជាចៅក្រម
៣-លោក ............ ជាចៅក្រមរបាយការណ៍
៤-លោក .............. ជាចៅក្រម
៥-លោក ................. ជាចៅក្រម

**ក្រឡាបញ្ជី**

-កញ្ញា ..................

**តំណាងមហាអយ្យការ**

-លោក ............ ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ១៩(ឈ)ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៥២៦ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០១របស់សាលាឧទ្ធរណ៍រវាង

ដើមចោទឈ្មោះថវឡ (ម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុសអាយុ៤៤ឆ្នាំ សញ្ជាតិ ខ្មែរមុខរបរពាណិជ្ជករ ទីលំនៅសព្វថ្ងៃផ្ទះលេខ៨៤៤E₀ ផ្លូវព្រះនរោត្តម សង្កាត់ផ្សារ កណ្តាលទីII ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះថាច់ ឈាង (ស្លាប់) ម្តាយឈ្មោះអ៊ុក ខុន មានកូន០១នាក់ ។

- មានមេធាវីលោក ទល។

ចុងចម្លើយឈ្មោះឈវត ភេទស្រី (ចុងបណ្តឹងសាទុក្ខ) អាយុ៤២ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់ដូរ ទីលំនៅផ្ទះ លេខ៨៤៤E₀ ផ្លូវនរោត្តម សង្កាត់ផ្សារ កណ្តាលទី២ ខណ្ឌដូនពេញ ក្រុងភ្នំពេញ។ ឪពុកឈ្មោះឈឹម រុំ ម្តាយឈ្មោះខៀវ ណារ៉ុន (រស់) មានកូនស្រីម្នាក់ ។

- មានមេធាវីលោក.............និងលោក............. ។

**កម្មវត្ថុបណ្តឹងៈ**ប្តឹងសុំផ្តាច់សមគ្គសង្វាស និង សុំចែកទ្រព្យសម្បត្តិរួម ក្រោយពីទូទាត់បំណុលរួចហើយ ។

បានឃើញបណ្ដឹងសាទុក្ខលេខ៩៥ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០២ របស់លោក............ (មេធាវីការពារក្ដីឱ្យលោកថវ៉ឡ) ប្ដឹងមិនសុខចិត្តនឹងសេចក្ដីសម្រេច របស់សាលាឧទ្ធរណ៍ ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១៨៦ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០២ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០០ របស់ដើមចោទឈ្មោះថវ៉ឡ ថាខ្លួន និងនាងឈវ៉ត បានរួមរស់ជាមួយគ្នាតាំងពីឆ្នាំ១៩៨៨ មក មានកូនស្រីម្នាក់ឈ្មោះថាច់ វ៉ត្ន កញ្ញានាមារី អាយុ០៤ ឆ្នាំ ។ រយៈពេលកន្លងទៅខ្លួន និងប្រពន្ធ រស់នៅមិនចុះសម្រុងគ្នា មិនអាចរស់នៅជាមួយគ្នា តទៅទៀតបានឡើយ ហើយសព្វថ្ងៃនេះបានបែកលំនៅ សង្វាសពីគ្នារួចដែរ ហេតុនេះខ្លួនសូមប្ដឹងសុំផ្ដាច់សមគ្គសង្វាស ពីប្រពន្ធឈ្មោះឈវ៉ត សុំចែកទ្រព្យសម្បត្តិរួម និងសុំយកកូនទៅចិញ្ចឹមថែរក្សា ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០០ របស់នាងឈវ៉ត ថាៈ លោកថវ៉ឡ បានលួចបើកក្រុមហ៊ុនថ្មី ឈ្មោះអិលអេសអេស សង់តាណា និងបើកគណនីថ្មីលេខ៣៣២ ០៤៦០៨ នៅធនាគារអង្គរ ដោយមិនបានឱ្យខ្លួនដឹងពីការធ្វើសេវាកម្មថ្មីទៀត ដែលមានគណនីលេខ០០០០ ៣៥៦៨ ២២៥ នៅធនាគារBNP នៅប្រទេសបារាំងហើយលោកថវ៉ឡ បានផ្ទេរថវិកា ពីក្រុមហ៊ុន អិលគេព្យួជ្យអស់ទៅហើយ ទើបគាត់ដាក់ពាក្យប្ដឹង ផ្ដាច់សមគ្គសង្វាសពីខ្លួនដែលអំពើទុកឱ្យខ្លួន និង កូន ត្រូវទទួលរងនូវបំណុលដ៏ច្រើនក្នុងក្រុមហ៊ុនចាស់ ហេតុនេះខ្លួនសុំប្ដឹងឃាត់ ការបន្តសេវាកម្មរបស់ក្រុមហ៊ុនអិលអសអេសសង់តាណា ចុះបញ្ជីពាណិជ្ជកម្មលេខ៨៤៥៥/៩៩P ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៩៩ របស់លោកថវ៉ឡ ជាបណ្ដោះអាសន្ន រង់ចាំតុលាការសម្រេចដល់ រឿងអង្គសេចក្ដី ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៦៣(ខ) ចុះថ្ងៃទី០៧ ខែធ្នូឆ្នាំ២០០០ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ :

១- ទទួលពាក្យបណ្ដឹងរបស់លោកថវ៉ឡ ជាដើមចោទ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០០ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- អោយលោកថវ៉ឡ និងនាងឈវ៉ត ដាច់សមគ្គសង្វាស់ពីគ្នា ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ តាមការព្រមព្រៀង របស់គូភាគី (យោងតាមមាត្រាទី៥៨ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ) ។

៣- អោយនាងឈវ៉ត ស្ថិតនៅក្នុងភាពមេម្វាយចំនួន៣០០ថ្ងៃ គិតពីថ្ងៃ នេះតទៅតាមមាត្រាទី៩ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

៤- ប្រគល់កូនស្រីម្នាក់ឈ្មោះថាច់ វ៉ត្នកញ្ញានាមារី អាយុ០៤ឆ្នាំ អោយទៅនាងឈវ៉ត ជាម្ដាយចិញ្ចឹមបីបាច់ថែរក្សាចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ប៉ុន្តែលោកថវ៉ឡ ជាឱពុកត្រូវបំពេញករណីកិច្ចរបស់ខ្លួនក្នុងការឧបត្ថម្ភជីវភាពកូនតាមលទ្ធភាព រហូតកូនមាននីតិភាព ។

- លោកថវឡ្យ ដែលមិនបានថែរក្សាកូនមានសិទ្ធិទៅសួរសុខទុក្ខកូន ឯនាងឈវត ដែលទទួលសិទ្ធិរក្សាកូនត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ភាគីម្ខាងទៀត ។

៥-ទ្រព្យសម្បត្តិរួមមានៈ

១-ផ្ទះសំអាងការលុច្យលេខ១៥0$E_0$ $E_1$ $E_2$ $E_3$ ផ្លូវលេខ១៤៨ សង្កាត់ផ្សារ កណ្ដាលទី២ ខណ្ឌដូនពេញ ក្រុងភ្នំពេញមានប័ណ្ណកម្មសិទ្ធិលេខ១៥២២៣ ។

២-ផ្ទះលេខ៥ បន្ទប់លេខ១១៩$E_3$ផ្លូវលេខ១៥៤ សង្កាត់ផ្សារកណ្ដាល២ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

៣-ផ្ទះពីរល្វែងលេខ១១៩$E_3$ ផ្លូវលេខ១៥៤ សង្កាត់ផ្សារកណ្ដាលទី២ខណ្ឌដូនពេញក្រុងភ្នំពេញ ។

៤-ទំនិញនិងសំភារៈបណ្ដាក់ក្នុងក្រុមហ៊ុន និងសំភារៈក្នុងហាងមានទឹកអប់ ម៉ាស្សា សំអាងការ ។

៥-រថយន្តមួយគ្រឿង ម៉ាក្សBMW លេខឃ០១៨៤ ភព២

៦-ប័ណ្ណ កម្មសិទ្ធិកាន់កាប់លេខ AV0332 ទំហំ20A ស្ថិតនៅភូមិវត្តបូណ៍ សង្កាត់លេខ០៤ទីរួម ខេត្តសៀមរាប ។

៧-ប័ណ្ណកម្មសិទ្ធិលេខG, 0275 ចំហំ14A46CAនៅភូមិចុងព្រែក ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

៨-ប័ណ្ណកម្មសិទ្ធិលេខកព០០០៧៩១ ទំហំ7A20CA នៅភូមិធ្វើខាងជើ ឃុំអណ្ដូងខ្មែរ ស្រុកកំពង់បាយ ខេត្តកំពត ។

៩-ប័ណ្ណកម្មសិទ្ធិកាន់កាប់លេខកព០០០៧៨៣ ទំហំ6A67CA នៅភូមិធ្វីខាង ជើងឃុំអណ្ដូង ខ្មែរ ស្រុកកំពង់បាយ ខេត្តកំពត ។

១០- ដីចំការម្នាស់មាន១០ប្លង់ទំហំ3H20A36CAនៅភូមិរលួស ឃុំបឹងទុកស្រុកកំពតខេត្តកំពត ។

១១-ដីកសិដ្ឋានចិញ្ចឹមសត្វ មានបីប្លង់ទំហំ11H51A02CAបឹងទុក ស្រុកកំពត ខេត្តកំពត ។

១២- ដីចំការមានមួយប្លង់ ទំហំ03H52A00CA នៅភូមិគីឡូ១២ ឃុំកោះតូច ស្រុកកំពត ខេត្តកំពត ។

១៣- ដីចំការ និងស្រែ មានបីប្លង់ទំហំ02H46A24CA ស្ថិតនៅភូមិរលួស ឃុំបឹងទុក ស្រុកកំពត ខេត្តកំពត ។

១៤-ដីនៅកើនដាច់លេខ0827 ត្រូវចែកគ្នាស្មើក្រោយពីអ្នកទាំងពីរ បានសងបំណុលរួមរួចហើយ ។

៧-បង្គាប់អោយលោកថវឡ្យ បង់ប្រាក់ប្រដាប់ក្ដីចំនួន៧០០០រៀល តាមការ ស្ម័គ្រចិត្តរបស់ខ្លួន គឺពន្ធហ្នឹងពន្ធចុះបញ្ជីក្ដី១.៨០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ៥.០០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០រៀល សរុប៧.០០០រៀល ប្រាក់នេះដើមចោទបានបង់រួចហើយ ។

៨-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខកចុងចំម្លើយ និងមេធាវីបើកផ្លូវប្តឹងទាស់ និងផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់របស់ឈ្មោះឈវត ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០០ ដោយស្នើសុំឱ្យលោកចៅក្រមធ្វើការជំនុំជំរះករណីនេះឡើងវិញ ដើម្បីឱ្យខ្លួនបានឆ្លើយការពារខ្លួនចំពោះមុខតុលាការផង ។

បានឃើញសាលក្រមលេខ៥៧ (ខ) ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារដូចតទៅ ៖

១- ទទួលពាក្យបណ្តឹងទាស់របស់ឈ្មោះឈវត ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០០ ទុកជាត្រឹមត្រូវ តាមទម្រង់ច្បាប់តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ៦៣(ខ) ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០០ ទុកជាបានការពេញទាំងមូល តាមច្បាប់ចាប់ពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០១ នេះតទៅ ។

៣- សាលក្រមនេះជំនុំជំរះ ជាសាធារណៈ ចំពោះមុខដើមបណ្តឹង និងមេធាវីការ សាវុត្ថ ............ និងចំពោះមុខចុងចម្លើយបណ្តឹងទាស់ ថវឡ និងមេធាវីចុង អៀវហេង ............បើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ១៥(ខ) ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០១ របស់អ្នកស្រីឈវតប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៤៤(ឈ) ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០១ របស់ឈ្មោះឈវត ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- បដិសេធសាលក្រមរដ្ឋប្បវេណីលេខ៥៧(ខ) ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ ២០០១ និងលេខ៦៣(ខ) ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០០ របស់តុលាការក្រុងភ្នំពេញចោលជាអសារបង់។

៣- បដិសេធពាក្យបណ្តឹងសុំផ្តាច់សមគ្គសង្វាស់ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០០ របស់ឈ្មោះថវឡ ចោលជាអសារបង់ ។

៤- ប្រគល់កូនស្រីម្នាក់ឈ្មោះថាច់ រ័ត្នកញ្ញានាមារី អាយុ០៤ឆ្នាំ ឱ្យទៅអ្នកស្រីឈវត ជាម្តាយចិញ្ចឹមបីបាច់ថែរក្សាតទៅ ចាប់ពីពេលដែលសាលដីកានេះចូលជាស្ថាពរ ។

៥- សម្រេចទុកសិទ្ធិឱ្យលោកថវឡ ទៅសួរសុខទុក្ខកូនបាន ។

៦- ប្រគល់ផ្ទះលេខ១៥$OE_0E_1$ $E_2$ $E_3$ ផ្លូវ១៤៨ សង្កាត់ផ្សារកណ្តាលទី២ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ដែលមានប័ណ្ណសំគាល់ម្ចាស់អចលនវត្ថុលោខ១៥២២៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៩៣ ឱ្យទៅអ្នកស្រីឈវត កាន់កាប់ជាកម្មសិទ្ធិតទៅ ។

៧- ទ្រព្យសម្បត្តិរួម ដែលមានតាមបញ្ជីរាយទ្រព្យសម្បត្តិរួមចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០០ លើកលែងតែផ្ទះលេខ១៥ OE$_0$E$_1$ E$_2$ E$_3$ ផ្លូវលេខ១៤៨ សង្កាត់ផ្សារកណ្ដាលទី២ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ដែលជាទ្រព្យដើមចេញ ត្រូវបែងចែកជាពីរស្មើគ្នា ចំពោះទ្រព្យណាដែលមានមុនលក្ខន្តិកៈក្រុមហ៊ុនLT LUX ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៤ ហើយទ្រព្យសម្បត្តិណា ដែលមានក្រោយថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៤ ត្រូវទុកឱ្យធ្វើការបែងចែកគ្នា ក្នុងបណ្ដឹងបែងចែកភាគហ៊ុន ។

៨- បង្គាប់ឱ្យគូភាគី រួមគ្នាសងបំណុល ដែលមានមុនថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៤ ហើយបំណុលដែលមានក្រោយថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៤ ត្រូវឱ្យគូភាគីសងតាមការសម្រេចក្នុងរឿង បែងចែកភាគហ៊ុន ។

៩- រឹបអូសប្រាក់ប្រដាប់ក្ដី ជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល ដែលឈ្មោះឈរតែ បានបង់រួចហើយ គឺពន្ធហ្នឹង និងពន្ធចុះបញ្ជីក្ដីចំនួន២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ ៥.០០០រៀល និងលើអាជ្ញាធរតុលាការ ៥.០០០រៀល សរុប ១៣.០០០រៀល ។

១០- សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខចុងចម្លើយនិង មេធាវីការពារចុងចម្លើយ កំបាំងមុខដើមចោទ បើកផ្លូវប្ដឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងទាស់លេខ៦៣ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០១របស់ឈ្មោះថវឡ ប្ដឹងមិន សុខចិត្តនិងសាលដីកាលេខ១៤៤ (ឈ) ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍លើសេចក្ដីសម្រេចទាំង មូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៩ (ឈ) ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១- ទទួលពាក្យបណ្ដឹងទាស់ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០១ របស់ឈ្មោះថវឡ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធប្រាលដោយទាស់ និងគតិច្បាប់ ។

២- តម្កល់សាលដីកាកំបាំងមុខលេខ១៤៤ (ឈ) ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០១របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

៣- សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្ដីបើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប ។

បានឃើញបណ្ដឹងសាទុក្ខលេខ៩៥ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០២របស់ឈ្មោះ............(មេធាវីរបស់ឈ្មោះថវឡ ប្ដឹងមិន សុខចិត្ត និងសាលដីកាលេខ១៩ (ឈ)ចុះថ្ងៃទី២៤ ខែមករាឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍លើសេចក្ដីសម្រេចទាំងមូល ។

បានឃើញសារណាការពារ ចុះថ្ងៃទី២៩ ខែ កក្កដា ឆ្នាំ ២០០២ របស់ឈ្មោះថវឡ។

បានឃើញសារណាតប ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ ២០០២របស់ឈ្មោះឈរតែ ។

បានឃើញសារណាបំភ្លឺបន្ថែម ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០២ របស់ឈ្មោះថវឡ ។

បានស្តាប់ចៅក្រមរបាយការណ៍អានរបាយការណ៍

បានស្តាប់តំណាងមហាអយ្យការ បានធ្វើសេចក្តីសន្និដ្ឋាន ថាៈ សាលដីការដ្ឋប្បវេណីលេខ១៤៤ (ឈ)ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសម្រេច ។

បានស្តាប់ចម្លើយរបស់ឈ្មោះថវឡ នៅពេលជំនុំជំរះថា បានជាខ្លួនបានប្តឹងសាទុក្ខព្រោះខ្លួនបានមិនសុខចិត្ត និងការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍លើបីចំណុចៈ

១-ការសម្រេចសេចក្តីផ្ទុយនឹងច្បាប់អាពាពិហ៍ពិពាហ៍

២- ការយល់ឃើញរបស់សាលាឧទ្ធរណ៍ មានភាពមិនប្រក្រតី

៣- ការសម្រេចសេចក្តី លើសសំណូមពរដោយសម្រេចយកទ្រព្យសម្បត្តិរួមអោយទៅជាទ្រព្យសម្បត្តិដើមរបស់នាងឈរតែ ហើយខ្លួន ក៏ដូចជានាងបានសុំបែងចែកពាក់កណ្តាលម្នាក់ ។ ហើយរឿងបំណុល សាលាឧទ្ធរណ៍បានសម្រេចអោយខ្លួន និងនាងរួមគ្នាសងទាំងម្ចាស់បំណុលមិនបានប្តឹងទាមទារផង ។ ហើយចំពោះផ្ទះលេខ១៥$OE_0E_1$ $E_2$ $E_3$ ខ្លួនបានលក់វេស្លង់ចតុមុខយកលុយ មកទិញផ្ទះនេះ ហើយដោយនាង វត្តី ជាអ្នកធ្វើការនៅនាយកដ្ឋាននោះស្រាប់ ទើបនាយកដ្ឋានដាក់ឈ្មោះនាង ។ នាងបានឈ្មោះ ជាម្ចាស់ផ្ទះនេះលួចទៅធ្វើប័ណ្ណគ្រួសារ និងធ្វើប័ណ្ណកម្មសិទ្ធិ ។

ខ្លួនសូមសំណូមពរតុលាការបែងចែកទ្រព្យសម្បត្តិជាពីរចំណែកស្មើគ្នា ។

បានស្តាប់ចម្លើយរបស់ឈ្មោះឈរតែ នៅពេលជំនុំជំរះថា ៖ នៅពេលដែលខ្លួនមាន ឯកសារគ្រប់គ្រាន់ ក្នុងការកាន់កាប់ផ្ទះ សំអាងការលួច្បនេះ ដោយមិនបានលួចលាក់ទៅធ្វើលិខិតអ្វីនោះទេ ព្រោះនៅជំនាន់នោះ ជាជំនាន់រដ្ឋកម្ពុជា លោកថានេះពុំត្រឹមត្រូវទេ គឺខ្លួនព្រមទាំងគ្រួសារទេ ដែលផ្ទិតមេដៃទទួលស្គាល់គាត់មកនៅក្នុងផ្ទះខ្លួន ។ នៅឆ្នាំ១៩៨៧ គាត់និយាយថា បើគាត់ជាអ្នកសាងសងផ្ទះនេះ សូមអោយគាត់បង្ហាញលិខិតទាំងនោះមក តាមការពិតគឺគាត់គ្មានលិខិតអ្វីទាំងអស់ ។ ហើយគ្មានលិខិតស្នាមណាដែលបញ្ជាក់ថាខ្លួន និងលោកថាន់ វ៉ាន់ឡុន ជាប្តីប្រពន្ធ និងគ្នានោះទេ ហើយទ្រព្យសម្បត្តិផ្សេងៗដែលសាលាឧទ្ធរណ៍កាត់ក្តីគឺជាទ្រព្យដែលបានកើតចេញពីក្រុមហ៊ុន LTLUX ។

បានស្តាប់ការសន្និដ្ឋានរបស់លោកមេធាវីទលនៅពេលជំនុំជំរះថា ខ្លួនសុំលើកពីរឿងពាក់ព័ន្ធនឹងប្តីប្រពន្ធ និងផ្ទះលេខ១៥០$E_0E_1$ $E_2$ $E_3$ ។ ចំពោះរឿងប្តីប្រពន្ធ ថ្វីត្បិតតែលោក និងអ្នកស្រីមិនបានចុះអេតាស៊ីវិលម៉ែន ប៉ុន្តែនៅជំនាន់នោះមានប្តីប្រពន្ធជាច្រើន ដែលមិនបានចុះអេតាស៊ីវិល ដោយអ្នកទាំងនោះរស់នៅជាមួយគ្នាមុនមានច្បាប់ លោកបានរស់នៅឆ្នាំ១៩៨៩ ដូច្នេះ គាត់ពុំបានចុះ អេតាស៊ីវិលទេ ហើយឆ្នាំ

២០០២ នេះ ច្បាប់បានចេញមកអោយអ្នកដែលគ្មានអេតាស៊ីវិល ទៅចុះអេតាស៊ីវិល ដូច្នេះបានន័យថា ច្បាប់នៅតែទទួលស្គាល់អ្នកដែលគ្មានអេតាស៊ីវិល ។ ចំពោះផ្ទះលេខ១៥$OE_0E_1$ $E_2$ $E_3$ ការផ្តល់អោយដោយនាយកដ្ឋានសិល្បៈនៅលើលិខិតនោះមានការកែបន្ថែមិ មានន័យថានាយកដ្ឋានបានប្រគល់អោយតែមួយចំណែក ។ ឆ្នាំ១៩៩៤ មានការប្រជុំគ្នាមួយទៀត ពេលនោះមានការដោះដូរ គឺខាងលោក និងអ្នកស្រីបានចេញប្រាក់ពីរម៉ឺនដុល្លា ចេញអោយទៅនាយកដ្ឋាន។ ដូច្នេះផ្អែកតាម ឯកសារបស់លោក និងគ្រួសារបញ្ជាក់ថា ផ្ទះនេះជាទ្រព្យសម្បត្តិរួម ព្រោះអ្នកទាំងពីរជាប្តីប្រពន្ធនឹងគ្នា ។ ចំណុចមួយទៀត សាលាឧទ្ធរណ៍សម្រេចលើសពីការស្នើសុំ ដូច្នេះសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍មានលក្ខណៈខុសឆ្គងទាំងទម្រង់ និងគតិច្បាប់។ ខ្លួនសុំអោយតុលាការមេត្តាបដិសេធសាលដីកានេះចោលទាំងស្រុង ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវីការ សាវុត្ថ នៅពេលជំនុំជំរះថា : ខ្លួនពុំលើកយកអង្គហេតុមកពិចារណាទេ គឺសុំលើកអង្គច្បាប់ ថាតើប្តីប្រពន្ធដែលស្របច្បាប់យ៉ាងណាព្រោះថា ចំណងអាពាហ៍ពិពាហ៍ធ្វើត្រូវស្របច្បាប់ និងតាមក្បួនខ្នាត ។ ហើយតាមច្បាប់អាពាហ៍ពិពាហ៍ ចំណងអាពាហ៍ពិពាហ៍មុនមិនទាន់រំលាយ មិនទាន់មានសាលក្រមលែងលះ យើងមិនអាចរៀបអាពាហ៍ ពិពាហ៍បានទេ គឺផ្ទុយ និងច្បាប់ ហើយចំពោះរដ្ឋធម្មនុញ្ញចែងច្បាស់ថា ប្តីមួយប្រពន្ធមួយ មិនមែនប្តីមួយ ប្រពន្ធពីរនេះទេ ដូច្នេះអ្នកស្រីនឹងលោកមិនមែនជាប្តីប្រពន្ធស្របច្បាប់នោះទេ ព្រោះលោកថវឡេ គាត់មានប្រពន្ធនៅប្រទេសបារាំង មិនទាន់បានធ្វើការលែងលះដាច់ស្រេចទេ ទើបនៅឆ្នាំ២០០០នេះ បានមានសាលក្រមលែងលះ ។ ហើយចំពោះទ្រព្យសម្បត្តិ អិលតេលុច្ប នេះមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ ថា របស់ឈវែត ចំពោះទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែក សូមអោយលោកមេធាវី............ ជាអ្នកបញ្ជាក់ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី............ នៅពេលជំនុំជំរះថាចំពោះអង្គហេតុខ្លួនបានការពារតាំងពីតុលាការថ្នាក់ក្រោមមក ខ្លួនបានសិក្សាគ្រប់គ្រាន់ពាក់ព័ន្ធ និងការរួមរស់ជាមួយគ្នារបស់អ្នកស្រី វត្តី និងលោកថវឡេ ។ សាលាឧទ្ធរណ៍បានសម្រេចសេចក្តីមកថា ភាគីទាំងពីរបានរស់នៅជាមួយគ្នាតាំងពីឆ្នាំ១៩៩០ នោះ គឺជាការយល់ឃើញតាមការអះអាងរបស់ភាគីទេ មិនមែនជាការសម្រេចរបស់តុលាការទេ ។ តែបើតាមភស្តុតាងគឺនៅឆ្នាំ១៩៩២ ទើបរស់នៅជាមួយគ្នា ហើយក្នុងពេលដែលអ្នកទាំងពីរស្រលាញ់គ្នា ទើបអ្នកស្រីប្រគល់សិទ្ធិអោយគាត់ ធ្វើជាមេគ្រួសារមិនមែនបញ្ជាក់ ថា គាត់ជាម្ចាស់ផ្ទះនោះទេ ហើយចំពោះលុយ២០០០០ដុល្លា គឺជាការទូទាត់បន្ទប់តូចមួយទេមិនមែន ទិញផ្ទះលេខ១៥$OE_0E_1$ $E_2$ $E_3$ និង$E_2$នោះទេ ។ ហើយចំពោះចំណងអាពាហ៍ពិពាហ៍ គឺដូចលោកមេធាវី ការ សាវុត្ថ បានលើកឡើងបញ្ជាក់ជូនរួចហើយ ។ ហើយក្នុងការដែលលោកថាច់ វ៉ាន់ឡុន ទទួលស្គាល់ថាជាប្តីប្រពន្ធនោះ គឺគាត់ខ្លាចមានទោសព្រហ្មទណ្ឌនោះទេ ដោយគាត់បានក្បត់ទំនុកចិត្តក្នុង រឿងព្រហ្មទណ្ឌលួចស៊ីញ៉េបិទក្រុមហ៊ុន ។ ហើយដែលថាសាលាឧទ្ធរណ៍សម្រេចលើសនោះ គឺសាលាឧទ្ធរណ៍ ពុំបានសម្រេចលើសទេ គឺគ្រាន់តែសម្រេចចតម្រូវតាមសាលក្រមរបស់តុលាការថ្នាក់ក្រោមដែលមិនបានពិចារណា ព្រោះនៅតុលាការថ្នាក់

ក្រោមគ្រាន់តែចប់ការដេញដោលតុលាការប្រកាសភ្លាម មិនបានធ្វើការ ពិភាក្សាទេ ។ ខ្លួនសុំសំណូមពរតុលាការ សូមអោយបែងចែកទ្រព្យសម្បត្តិតាម អធិការកិច្ច ព្រោះភាគ ហ៊ុន និងបំណុលផ្សេងៗ អធិការកិច្ចបានធ្វើការបែងចែកនៅក្នុងកំណត់ហេតុនោះស្រាប់ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវីទលនៅពេលជំនុំជំរះថា: តបទៅនឹង លោកមេធាវី ការសាវុត្ត ថា អ្នកស្រីគ្មានភស្តុតាងណាបញ្ជាក់ថា ជាប្តីប្រពន្ធនឹងគ្នា ខ្លួនទៅតែសុំបញ្ជាក់ ដដែល ថាកាលពីសម័យនោះមិនទាន់មានការចុះអេតាស៊ីវិលទេ គឺរស់នៅជាមួយគ្នាមុនច្បាប់ចេញ ។ ប្រភពពីការធ្វើប័ណ្ណកម្មសិទ្ធិដើម្បី ស្រាវជ្រាវទ្រព្យសម្បត្តិនេះ អ្នកស្រីក៏បានទទួលស្គាល់ថា លុយ២០.០០០ ដុល្លានេះ ជាលុយរួមដូរនិងបន្ទប់មួយ នេះគឺជាទ្រព្យសម្បត្តិរួមដែរ ហើយចុះលួយថ្លៃជួសជុលផ្ទះនោះក៏ជាឈ្នួលរួមដែរ សូមតុលាការពិចារណាចំពោះរឿងនេះ ។ លោកមេធាវី............ ថា កូនក្តីខ្លួនមានរឿងព្រហ្មទណ្ឌនោះមិនអាចកើតមានឡើងបានទេ ទោះបីជាលោកនៅអសង្ហាសបុគ្គលក៏ដោយ ។ ដូចនេះខ្លួននៅតែសុំអះអាងដដែលដែរថាសាលាឧទ្ធរណ៍សម្រេចលើសពីការស្នើសុំដដែល ។

បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់លោកមេធាវីការ សាវត្ត នៅពេលជំនុំជំរះថា៖ ចំពោះរឿងលុយ២០០០០ដុល្លា និងលុយថ្លៃជួសជុលគឺតុលាការសម្រេចអោយទៅអ្នកស្រីចិញ្ចឹមកូន ព្រោះអ្នកស្រីបានចិញ្ចឹមកូនតែម្នាក់ឯង ។

បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់លោកមេធាវី............ នៅពេលជំនុំជំរះថាសាលាឧទ្ធរណ៍មិនបានសម្រេចលើសទេ ព្រោះនៅក្នុងចំណុចទី៧ សាលាឧទ្ធរណ៍បានសម្រេចសារឡើងវិញ ហើយបានអះអាងពីបញ្ហាសងបំណុលក្តី និងបញ្ហាបែងចែកទ្រព្យសម្បត្តិក្តីគឺសាលាឧទ្ធរណ៍សម្រេចគ្រប់ គ្រាន់ហើយមិនលើសទេ ។ សំណូមពរចុងក្រោយសូមអោយតុលាការតម្កល់សាលដីកាសាលាឧទ្ធរណ៍ ។

បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់លោកមេធាវីទលនៅពេលជំនុំជំរះថា៖ ទ្រព្យសម្បត្តិនៅឆ្នាំ១៩៩៤ ជាទ្រព្យសម្បត្តិរួម ដូច្នេះត្រូវបែងចែក៣០% ទៅ៧០%មិនត្រូវបែងចែក៧០%មក៣០% នោះទេ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវី គូភាគី ។
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៩៥ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០២ របស់លោក............ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការលើករឿងរបស់លោកថវឡ ក្នុងសារណាចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០២ ថាលោក និងអ្នកស្រីឈវត ជាប្តីនិងប្រពន្ធនឹងគ្នា ដោយសំអាងលើសៀវភៅស្នាក់នៅលេខ ១០៤៩ ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ១៩៩៩ ប័ណ្ណគ្រួសារលេខ២២D ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៦ និងលេខ២២D ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៣ ប័ណ្ណកម្មសិទ្ធិផ្ទះសំអាងការលុច្ប សំបុត្រកំណើតកូនចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៩៥ ចម្លើយរបស់អ្នកស្រីឈវត ក្នុងកំណត់ហេតុចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០០ និងលិខិតអ្នកស្រីឈវត ផ្ញើរជូនធនាគារអេង្គរ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ នោះគឺជាការភ័ន្តច្រឡំពីព្រោះថា :

+ តាមចម្លើយលោកថវឡ ខ្លួនឯងនាសវនាការនៅតុលាការថ្នាក់ក្រោម ថាខ្លួនពិតជាបានរួមរស់ជាមួយអ្នកស្រីឈវត ដោយពុំបានរៀបការ រឺចុះសំបុត្រអាពាហ៍ពិពាហ៍ តាមលក្ខណៈច្បាប់ឡើយ តែលោក និងអ្នកស្រីឈវត ពិតជាមានកូនស្រីម្នាក់ជាមួយគ្នាប្រាកដមែន ។

+ តាមអំណាចសាលក្រមលេខRG៩៤០៣០៥១ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៩៥ របស់តុលាការទីក្រុង វ៉ាឡង់ប្រទេសបារាំង បញ្ជាក់ឱ្យឃើញថា៖តុលាការទើបបានបំបែកលំនៅសង្វាស រវាងខ្លួនលោក ថវឡ និងប្រពន្ធលោកឈ្មោះថាច់ ធីចន្ថា ជាបណ្តោះអាសន្ន ហើយទើបមកដល់ឆ្នាំ២០០០ តុលាការដដែលបានសម្រេច រំលាយចំណងអាពាហ៍ពិពាហ៍របស់អ្នកទាំងពីរ ។

+ តាមលិខិតបញ្ជាក់លេខ១៩៥ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០១ របស់អ្នកស្រីប៉ែន អ៊ិន ចៅសង្កាត់ផ្សារកណ្តាល បញ្ជាក់ថា អ្នកស្រីឈវត និងលោកថវឡ ពុំបានរៀបការនិងចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នា ក្នុងបញ្ជីអត្រានុកូលដ្ឋាននៅសង្កាត់ផ្សារកណ្តាលនេះទេ ។ បើទោះជាលោកថវឡ និងអ្នកស្រីឈវត ជាប្តីប្រពន្ធពេញលេញច្បាប់ក៏ដោយ ក៏ចំណងអាពាហ៍ពិពាហ៍នេះត្រូវមោឃៈភាពដោយមាត្រា ៣.៦.២៤.៣៨ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ និងមាត្រា៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែរ ។

- យល់ឃើញថា ផ្ទះសំអាងការលុច្ប ស្ថិតនៅផ្លូវលេខ៤១ កែងផ្លូវ១៤៨ សង្កាត់ផ្សា កណ្តាល ខណ្ឌដូនពេញ ដែលលោកថវឡ ថាជាសម្បត្តិរួមប្តីប្រពន្ធនោះគឺពុំត្រឹមត្រូវទេពីព្រោះថាៈ

+ មានភស្តុតាងបញ្ជាក់ថាផ្ទះលេខ១៥$OE_0E_1$ $E_2$ $E_3$ពិតជាកម្មសិទ្ធិដើមដោយឡែករបស់អ្នកស្រីឈវត និងសមាជិកគ្រួសារក្នុងបន្ទុក មុនពេលរួមរស់ជាមួយលោកថវឡ តាមលិខិតបញ្ជាក់លេខ១២៨/៩២ លម ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩២ របស់ចៅសង្កាត់ ផ្សារកណ្តាល បញ្ជាក់ថា នាងឈើម វត្តី ជាសិល្បៈការនី ក្រសួងឃោសនាការវប្បធម៌ ជាម្ចាស់ផ្ទះលេខ១៥$OE_0E_1E_2E_3$ ដែលមានប័ណ្ណគ្រួសារលេខ ៤៨០ សៀវភៅលេខ២២D រស់នៅក្នុងមូលដ្ឋានសង្កាត់ផ្សារកណ្តាល ប្រាកដមែន ។

+ តាមវិញ្ញាបនប័ត្រសំគាល់ម្ចាស់ អចលនវត្ថុ(ដើម) ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩២ បញ្ជាក់ថា នាងឈវត ជាមេគ្រួសារ និងជាម្ចាស់ពិតប្រាកដលើអចលនវត្ថុនេះតែម្នាក់ឯងដោយមានចុះហត្ថលេខាសមាជិកគណកម្មការចំរុះឈ្មោះឃី ម៉ាច និងនូវ គឹមសួន ទៀតផង ស្របទៅ និងលិខិតអនុញ្ញាតិ របស់

នាយកដ្ឋានសិល្បៈ និងទស្សនីយភាព របស់ក្រសួងឃោសនាការ និងវប្បធម៌ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ១៩៩១ គឺបានប្រគល់ផ្ទះសំអាងការលុច្ប លេខ១៥០$E_0E_1E_2E_3$ អោយអ្នកស្រីឈវត ដែលជាអតីតសិល្បការនី មុនពេលជួបលោកថវឡ ផងដែរ ។

- យល់ឃើញថា ការដែលមេធាវីដើមចោទ លើកឡើងថា ប្រាក់២០.០០០ដុល្លា ដែលអ្នកស្រីឈវត យកទៅទូទាត់ក្នុងការផ្ទេរសំអាងការលុច្ប ពីនាយកដ្ឋានសិល្បៈ និងទស្សនីយភាពថា ជាប្រាក់ដែលអ្នកស្រីឈវត បានមកពីការរកស៊ីក្នុងក្រុមហ៊ុនជាមួយលោកថវឡ ដូច្នេះផ្ទះនេះជាសម្បត្តិរួមនោះ គឺជាការពុំត្រឹមត្រូវទេ ពីព្រោះក្នុងការប្រកបមុខរបរនេះអ្នកស្រីឈវត និងលោកថវឡ ស្ថិតក្នុងស្ថានភាពជាសមាជិក ភាគហ៊ុនដូចគ្នា ដែលតាមលក្ខន្តិក នៃក្រុមហ៊ុនគឺ៧០%៣០% ។

-យល់ឃើញថា ការដែលលោកថវឡក្តី មេធាវីរបស់លោកក្តីអះអាងថាប័ណ្ណសំគាល់សិទ្ធិកាន់កាប់មានបញ្ជាក់ថា ផ្ទះលេខ១៥០ ជាទ្រព្យរួមប្តីប្រពន្ធនោះគឺជាការពុំត្រឹមត្រូវទេ ពីព្រោះថាប័ណ្ណកម្មសិទ្ធិនេះធ្វើឡើង នៅលើមូលដ្ឋាន នៃប្រកាសរបស់សាមីខ្លួនដែលមិនត្រឹមត្រូវតាម ច្បាប់ ។

- យល់ឃើញថា ការដែលលោកថវឡក្តី មេធាវីរបស់លោកក្តីអះអាងថាផ្ទះ លេខ១៥ $OE_0E_1E_2E_3$ នេះលោកមិញពីនាយកដ្ឋានសិល្បៈ និងទស្សនិយភាពនោះពុំមានភស្តុតាង ណាមួយបញ្ជាក់អំពីការអះអាងនេះទេ ។

យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចត្រង់ចំណុចទី៧ នៃសាលដីកាកំបាំងមុខលេខ ១៤៤(ឈ) ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០១ ដែលត្រូវបានសាលាឧទ្ធរណ៍តម្កល់ទុកជាបានការ តាមសាលដីកាចំពោះមុខលេខ១៩ (ឈ) ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០២ គឺជាការភ័ន្តច្រឡំពីព្រោះតាមពាក្យបណ្តឹងចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០០ អ្នកស្រីឈវត បានប្តឹងឃាត់សកម្មភាព របស់ក្រុមហ៊ុន អិលអសអេស សង់តាណា ជាបណ្តោះអាសន្ន រង់ចាំការសម្រេចដល់អង្គសេចក្តីដែលគប្បីសាលាឧទ្ធរណ៍ពិចារណាឡើងវិញ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១៩(ឈ) ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែអំពីគតិច្បាប់ខុសខ្លះត្រូវខ្លះ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខ គូក្តី**

១- ទទួលបណ្តឹងសាទុក្ខលេខ៩៥ ចុះថ្ងៃទី១៣ ខែ០៣ ឆ្នាំ២០០២ របស់លោកមេធាវីទលទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែអំពីគតិច្បាប់ខុសខ្លះត្រូវខ្លះ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ១៩(ឈ) ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ទុកជាបានការលើកលែងចំណុចទី៧ នៃសាលដីកាកំបាំងមុខលេខ១៤៤(ឈ) ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០១ ដែលត្រូវទុកជាមោឃៈ ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១៨៦ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០២ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះ ត្រង់ចំណុចទី៧ នៃសាលដីកាកំបាំងមុខលេខ១៤៤(ឈ)ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលអ្នកស្រីឈរតេ បានបង់គឺ :

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

- ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវឱ្យលោកថាច់ វាន់ឡុន សងប្រាក់ចំនួន៩.៥០០រៀល ទៅឱ្យអ្នកស្រីឈរតេ វិញ ។

៥- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០២ ។